# ការបង្ការការរីករាលដាល នៃជំងឺផ្លូវដង្ហើម នៅតាមផ្ទះ

## លាងសម្អាតដៃរបស់អ្នកឲ្យបានស្អាត និងញឹកញាប់

- លាងសម្អាតដៃរបស់អ្នកឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកឲ្យបានយ៉ាងតិច 20 វិនាទី។
- បើមិនមានសាប៊ូ និងទឹក ចូរប្រើទឹកអនាម័យលាងដៃដែលមានជាតិអាល់កុលយ៉ាងតិច 60%។
- លាងសម្អាតដៃរបស់អ្នកបន្ទាប់ពីចាក់ធុងសម្រាម ប៉ះក្រដាសជូតមាត់ ឬកាកសំណល់ស្រដៀងគ្នា។

## អានស្លាកនៅលើផលិតផលសម្អាត

- អនុវត្តតាមការណែនាំនៅលើស្លាកផលិតផល រួមទាំងពាក់ស្រោមដៃ និងមានខ្យល់ចេញចូលល្អ។
- ប្រើផលិតផលសម្អាតតាមផ្ទះ និងសារធាតុសម្លាប់មេរោគដែលបានចុះបញ្ជិការជាមួយភ្នាក់ងារការពារបរិស្ថាន (Environmental Protection Agency; EPA) ដែលសមស្របសម្រាប់ផ្ទៃ។
- ដើម្បីស្វែងយល់ថាតើផលិតផលមានប្រសិទ្ធភាពចំពោះមេរោគឬក៏អត់ ចូរអានស្លាកផលិតផល ទូរសព្ទទៅលេខ 1-800 នៅលើស្លាក ឬចូលទៅកាន់គេហទំព័រ www.epa.gov
- សូលុយស្យុងធ្វើឲ្យស (Bleach) ក៏អាចប្រើជាសារធាតុសម្លាប់មេរោគផងដែរ - លាយ Bleach 4 ស្លាបព្រាកាហ្វេ ទៅក្នុងទឹក 1 ក្វាត (4 ពែង ឬ 946 មល) ឬសម្រាប់ការផ្គត់ផ្គង់ច្រើនជាងនេះ ដាក់ Bleach 1/3 ពែងក្នុងទឹក 1 ហ្គាឡុង (16 ពែង)។

## សម្អាត និងសម្លាប់មេរោគលើវត្ថុ និងផ្ទៃដែលប៉ះពាល់ច្រើនឲ្យបានញឹកញាប់

**ផ្ទៃរឹង (មិនមានរន្ធ)**

*ឧ. ផ្ទៃដែលប៉ះពាល់ច្រើនដូចជា ផ្ទៃធ្វើការ ផ្ទៃខាងលើតុ ដៃទ្វារ របារការពារ ប្រដាប់ប្រដាបន្ទប់ទឹក កុងតាក់ភ្លើង បង្គន់ ទូរសព្ទ ក្តារចុច តេឡេបញ្ជា ថេប្លិត និងតុក្បែរគ្រែគេង។*

- សម្អាតផ្ទៃ និងវត្ថុដើម្បីកម្ចាត់ធូលីដែលអាចមើល និងសម្លាប់មេរោគ។ នៅពេលប្រើប្រាស់សារធាតុចម្លាប់មេរោគ ចូរធ្វើឲ្យប្រាកដថាផ្ទៃនៅតែសើមរយៈពេលយ៉ាងតិច 10 នាទី រួចលាងសម្អាតជាមួយទឹក ជាពិសេសនៅកន្លែងដែលប៉ះពាល់ជាមួយម្ហូបអាហារ។ ទុកឲ្យវាស្ងួតដោយសារខ្យល់។
- អានការណែនាំដោយប្រុងប្រយ័ត្ន នៅពេលប្រើក្រណាត់ជូតសម្លាប់មេរោគនៅលើគ្រឿងអេឡិចត្រូនិកដោយធ្វើឲ្យប្រាកដថា ពួកគេអាចធន់ទ្រាំនឹងការប្រើប្រាស់ក្រដាស់ជូតច្រើន ដែលចាំបាច់ដើម្បីរក្សាឲ្យផ្ទៃសើមបានយូរគ្រប់គ្រាន់ ដើម្បីបំពេញតាមរយៈពេលប៉ះពាល់ដែលបានតម្រូវ។

**ផ្ទៃទន់ (មានរន្ធ)**

*ឧ. កន្សែង កម្រាលពូកស្រោមខ្នើយ សំលៀកបំពាក់ និងតុក្កតាញាត់សំលី។*

- បោកគក់ជាមួយទឹកក្តៅ ដោយប្រើម្សៅសាប៊ូបោកខោអាវតាមផ្ទះ និងហាលវានៅកន្លែងដែលមានកម្តៅខ្លាំង

## សម្រាប់ព័ត៌មានបន្ថែម

សេចក្តីណែនាំរបស់ CDC អំពីការសម្អាត និងការសម្លាប់មេរោគនៅតាមផ្ទះដែលសង្ស័យ ឬបញ្ជាក់ថាមានជំងឺរលាកផ្លូវដង្ហើមកូរ៉ូណាឆ្នាំ 2019៖
https://www.cdc.gov/coronavirus/2019-ncov/community/home/cleaning-disinfection.html#disinfect

សេចក្តីណែនាំរបស់ Public Health អំពីរបៀបលាងសម្អាតដៃរបស់អ្នកឲ្យបានត្រឹមត្រូវ៖
http://publichealth.lacounty.gov/media/Coronavirus/ (ចុចលើម៉ឺនុយលាងសម្អាតដៃ)